ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះវិហារ

សំណុំរឿងរដ្ឋប្បវេណីលេខ ៩៩
ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០
សាលក្រមរដ្ឋប្បវេណី
លេខ ០២ (ច)
ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះវិហារ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដោយមានសមាសភាព:

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ
អមដោយ លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

**ភាគីដើមចោទ**

ឈ្មោះ [redacted] វិសាល ភេទប្រុស កើតថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៨០ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរគ្រូកីឡា មានអាសយដ្ឋាន [redacted]។

មានលោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**ភាគីចុងចម្លើយ**

ឈ្មោះ [redacted] គឹមអាត ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៨២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរលក់ដូរ មានអាសយដ្ឋាន [redacted]។

**អង្គហេតុ និងចំណុចវិវាទ:**

**១ ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:**

១.១.សុំលែងលះពីប្រពន្ធឈ្មោះ [redacted] **គឹមអាត**។

១.២.សុំប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន ០២នាក់ ឈ្មោះ [redacted] បញ្ញាពេជ្រ ភេទស្រី កើតថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៣ និងកូនទី២ ឈ្មោះ [redacted] បញ្ញាមរកត ភេទស្រី កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤ ឲ្យចុងចម្លើយឈ្មោះ [redacted] **គឹមអាត** ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា។

១.៣.ទ្រព្យសម្បត្តិរួមគ្មាន។

១.៤.ប្រាក់ប្រដាប់ក្តីរបស់ជាបន្ទុករបស់ដើមចោទ។

**២.ការពន្យល់ត្រួសៗ អំពីរឿងក្តី**

តាមពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ដើមចោទថា កាលពីអំឡុងឆ្នាំ ២០០២ ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងចុងចម្លើយឈ្មោះ [redacted] **គឹមអាត** តាមប្រពៃណី និងទំនៀមទំលាប់ ក្រោមប្រឹក្សាញាតិបានដឹងលឺ និងក្រោយមកភាគីបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់ ដែលមានលេខ ៣៣ សៀវភៅអាពាហ៍ពិពាហ៍លេខ ០២/២០០៣ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ចំពោះមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ជាភស្តុតាង។ ក្នុងការរួមរស់ជាប្តីប្រពន្ធកន្លងមក ភាគីបង្កើតបានកូនចំនួន ០២នាក់ កូនទី១ ឈ្មោះ [redacted] បញ្ញាពេជ្រ ភេទស្រី កើតថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៣ និងកូនទី២ ឈ្មោះ [redacted] បញ្ញា



Scanned with CamScanner

មរកត ភេទស្រី កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤។ មូលហេតុដែលដើមចោទប្ដឹងស្នើសុំលែងលះពីចុងចម្លើយដោយសារ ការរស់នៅមិនចុះសម្រុងនឹងគ្នា មិនទុកចិត្ត រស់នៅជាមួយគ្នាតែងតែរកាំរកូស ដែលជាហេតុធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធបន្តទៅទៀត។

## ៣. **ការអះអាងរបស់គូភាគី**

### ៣.១.ការអះអាងរបស់ដើមចោទ

ដើមចោទឈ្មោះ [redacted]វិសាល បានធ្វើសេចក្ដីថ្លែងការណ៍ថា នៅពេលនេះ ខ្លួននៅប្ដឹងសុំដូចកម្មវត្ថុបណ្ដឹងដដែល ដោយនៅតែប្ដឹងសុំលែងលះពីប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] **គឹមអាត** ដោយមូលហេតុថា ការរស់នៅមិនចុះសម្រុងនឹងគ្នា ដោយប្រពន្ធរបស់ខ្លួនរករឿងខ្លួន ទាំងខ្លួនមិនមានកំហុស មើលងាយរូបខ្លួនជាប្ដី ពេលបាត់លុយ គាត់ចោទថាខ្លួនយក ហើយនិយាយប្រាប់គេផ្សេងៗទៀត ធ្វើឲ្យខ្លួនខ្មាសគេ ពេលគាត់ខឹងខ្លួន គាត់បានអុជធូបនៅនឹងចុងជើងរបស់ខ្លួន ពេលខ្លួនគេងលក់ ខ្លួនមិនដឹងថាមានគោលបំណងអ្វីឡើយ ប្រពន្ធខ្លួនតែងតែនិយាយជាការសរសេរជាអក្សរលើបណ្ដាញសង្គមហ្វេសបុកមើលងាយខ្លួនជាប្ដី ម្យ៉ាងទៀត ខ្លួនលែងមានទំនុកចិត្តក្នុងការរួមរស់ជាប្ដីប្រពន្ធទៀតហើយ ខ្លួនលែងមានក្ដីស្រលាញ់ជាមួយគាត់ទៀតហើយ ដែលជាហេតុជាធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធតទៅទៀត។ ខ្លួន និងប្រពន្ធខ្លួន បានគ្នាជាប្ដី-ប្រពន្ធ កាលពីអំឡុងឆ្នាំ២០០២ ដោយបានរៀបការជាមួយគ្នាតាមប្រពៃណី និងទំនៀមទំលាប់ខ្មែរ ដោយមានក្រុមប្រឹក្សាញាតិដឹងលឺ ហើយក្រោយមកក៏បាននាំគ្នាចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់ ដែលមានលេខ ៣៣ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០០៣ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ចំពោះមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធ កន្លងមកបង្កើតបានកូន ០២នាក់ កូនទី១ ឈ្មោះ [redacted] បញ្ញាពេជ្រ ភេទស្រី កើតថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៣ និងកូនទី២ ឈ្មោះ [redacted] បញ្ញាមរកត ភេទស្រី កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤។ បច្ចុប្បន្ននេះ កូនទាំង០២នាក់នេះ កំពុងស្ថិតនៅក្រោមការគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សារបស់ប្រពន្ធខ្លួន និងខ្លួន។ ខ្លួនស្នើសុំប្រគល់សិទ្ធិមានអំណាចមេបាលើកូនទាំង ០២នាក់នេះ ឲ្យប្រពន្ធខ្លួន ដោយស្នើសុំផ្ដល់ប្រាក់ជាសោហ៊ុយចាំបាច់សម្រាប់មើលពួកគាត់ទាំង ០២រូប ក្នុងមួយខែៗ ចំនួន ៤០០.០០០៛ (សែសិបម៉ឺនរៀល)។ ចំពោះទ្រព្យសម្បត្តិរួម និងបំណុលរួមរវាងខ្លួន និងប្រពន្ធខ្លួនពុំមានឡើយ។ ចំពោះប្រាក់ប្រដាប់ក្ដី និងប្រាក់បង់ពន្ធផ្សេងៗ ខ្លួនសុខចិត្តទទួលបន្ទុកបង់ទាំងស្រុង។

### ៣.២.ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] **គឹមអាត** បានធ្វើសេចក្ដីថ្លែងការណ៍ថា ខ្លួនក៏ឯកភាពតាមការប្ដឹងសុំលែងលះពីប្ដីរបស់ខ្លួនឈ្មោះ [redacted] វិសាល ដែរ ដោយមូលហេតុថា ការរស់នៅមិនចុះសម្រុងនឹងគ្នា អស់ក្ដីស្រលាញ់ ដែលជាហេតុធ្វើឲ្យខ្លួនឯកភាពតាមការប្ដឹងសុំលែងលះរបស់ប្ដីខ្លួន។ ខ្លួន និងប្ដីរបស់ខ្លួនពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្ដីប្រពន្ធ តាមប្រពៃណី និងទំនៀមទំលាប់ខ្មែរ កាលពីអំឡុងឆ្នាំ២០០២ ប្រាកដមែន និងក្រោយមកក៏បាននាំគ្នាចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់រួចហើយដែរ។ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាជាប្ដីប្រពន្ធកន្លងមក ខ្លួន និងប្ដី



Scanned with CamScanner

ខ្លួនពិតជាបង្កើតបានកូនចំនួន ០២នាក់ ដូចដែលប្តីរបស់ខ្លួនបានថ្លែងការណ៍មានឈ្មោះ និងថ្ងៃខែឆ្នាំកំណើតខាងលើប្រាកដមែន។ ចំពោះការស្នើសុំប្រគល់អំណាចមេបាលើកូនទាំង០២នាក់នេះពីប្តីរបស់ខ្លួននោះ ខ្លួនឯកភាពទទួលយកសិទ្ធិជាអ្នកមានអំណាចមេបា។ ចំពោះប្រាក់សោហ៊ុយចាំបាច់សម្រាប់មើលថែរក្សាកូនទាំង០២នាក់នេះ ខ្លួនឯកភាពទទួលយកចំនួន ៥០០.០០០៛ (សែសិបម៉ឺនរៀល) ក្នុងមួយខែៗ។ ចំពោះទ្រព្យសម្បត្តិរួម និងបំណុលរួមរវាងខ្លួន និងប្តីរបស់ខ្លួនពុំមានឡើយ។ បច្ចុប្បន្ននេះខ្លួនពុំមានផ្ទៃពោះឡើយ។ ប្រាក់ប្រដាប់ក្តីតុលាការ ខ្លួនឯកភាពតាមការអះអាងរបស់ប្តីរបស់ខ្លួន។

**៤. ចំណុចវិវាទ និងចំណុចគ្មានវិវាទ:**

៤.១.ចំណុចវិវាទ: គ្មាន។

៤.២.ចំណុចគ្មានវិវាទ:

-ភាគីព្រមព្រៀងលែងលះ

-ភាគីព្រមព្រៀងសិទ្ធិមានអំណាចមេបាលើកូនទាំង ០២នាក់ ប្រគល់ឲ្យចុងចម្លើយជាម្តាយគ្រប់គ្រង

-ភាគីព្រមព្រៀងគ្នាលើប្រាក់ជាសោហ៊ុយចាំបាច់សម្រាប់មើលថែរក្សាកូន

-ភាគីព្រមព្រៀងគ្នាលើប្រាក់ប្រដាប់ក្តីតុលាការ។

## **សំអាងហេតុ**

-តាមលទ្ធផលនៃការត្រៀមសម្រាប់ការទាញហេតុផល និងការពិនិត្យភស្តុតាងនានាក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

១.ភាគីដើមចោទឈ្មោះ [redacted] **វិសាល** បានធ្វើសេចក្តីថ្លែងការណ៍ដូចមាននៅក្នុងពាក្យបណ្តឹងថា៖ ខ្លួន និងប្រពន្ធខ្លួនពិតជាបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធស្របច្បាប់ប្រាកដមែន ដោយបានរៀបការតាមប្រពៃណី និងទំនៀមទំលាប់ កាលពីអំឡុងឆ្នាំ២០០២ និងក្រោយមកបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នារួចហើយដែរ។ ភាគីចុងចម្លើយឈ្មោះ [redacted] **គឹមអាត** ក៏បានធ្វើសេចក្តីថ្លែងការណ៍ស្របទៅនឹងសេចក្តីថ្លែងកាណ៍របស់ភាគីដើមចោទដែរ។ សេចក្តីថ្លែងការណ៍របស់ភាគីបានភ្ជាប់មកជាមួយនូវភស្តុតាងសំបុត្រអាពាហ៍ពិពាហ៍លេខ ៣៣ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០០៣ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ចំពោះមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ អាចឲ្យតុលាការទទួលស្គាល់នូវអានុភាពនៃអាពាហ៍ពិពាហ៍ តាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ហើយពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ បានធ្វើឡើងតាមទម្រង់ និងក្រោមកំណត់ច្បាប់ គប្បីតុលាការ ទទួលយកបណ្តឹងរបស់ដើមចោទមកពិនិត្យ និងសម្រេចតាមច្បាប់។

២.នានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ភាគីដើមចោទនៅតែប្តឹងសុំលែងលះពីចុងចម្លើយ ប៉ុន្តែនៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុងចម្លើយមិនឯកភាពលែងលះឡើយ។ ក្រោយពីតុលាការបានបើកនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយក៏បានបង្ហាញឆន្ទៈឯកភាពលែងលះពីដើមចោទ នេះជាមូលហេតុមានចែងក្នុងមាត្រា ៩៧៨ កថាខណ្ឌ១ ចំណុច(ង) នៃក្រមរដ្ឋប្បវេណី គប្បីតុលាការធ្វើការពិចារណា និងសម្រេចតាម



Scanned with CamScanner

ការព្រមព្រៀងរបស់ភាគី។

៣. ភាគីដើមចោទ និងចុងចម្លើយបានអះអាងស្របគ្នាថា អំឡុងពេលរួមរស់ជាមួយគ្នាបង្កើតបានកូន០២នាក់ កូនទី១ ឈ្មោះ [redacted]បញ្ញាពេជ្រ ភេទស្រី កើតថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៣ និងកូនទី២ ឈ្មោះ [redacted] បញ្ញាមរកត ភេទស្រី កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤។ ការអះអាងរបស់ភាគីបានដាក់បញ្ចូលភស្តុតាងសំបុត្រកំណើតលេខ ៨០ សៀវភៅកំណើតលេខ ០២/២០០៥ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៥ និងសំបុត្រកំណើតលេខ ២៦ សៀវភៅកំណើតលេខ ០១/២០១៤ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។ ភាគីដើមចោទបានបង្ហាញឆន្ទៈស្នើសុំប្រគល់អំណាចមេបាលើកូនទាំង ០២នាក់នេះ ឲ្យចុងចម្លើយជាម្ដាយ ចុងចម្លើយក៏បានបង្ហាញឆន្ទៈឯកភាព គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី តាមបញ្ញត្តិមាត្រា ១០៣៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ដោយឡែកភាគីដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន នៅក្នុងពេលវេលាដែលសមរម្យ។ ភាគីដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៤.ភាគីដើមចោទបានស្នើសុំផ្ដល់ប្រាក់ជាសោហ៊ុយចាំបាច់ សម្រាប់ដើម្បីគ្រប់គ្រង និងមើលថែរក្សាកូនក្នុងមួយខែៗ ចំនួន ៥០០.០០០៛ (សែសិបម៉ឺនរៀល) ភាគីចុងចម្លើយឯកភាព និងព្រមព្រៀងទទួលការផ្ដល់ប្រាក់ជាសោហ៊ុយនេះពីដើមចោទ។ តុលាការយល់ឃើញថា ដើម្បីការពារឧត្តមប្រយោជន៍របស់កុមារ ព្រមទាំងការស្នើសុំផ្ដល់ប្រាក់ជាសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រង និងថែរក្សានេះ មានលក្ខណៈសមរម្យ ធៀបនឹងកំរិតជីវភាពរបស់ដើមចោទ ហេតុដូច្នេះ គប្បីតុលាការពិចារណា និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៥.ភាគីដើមចោទ និងចុងចម្លើយបានអះអាងស្របគ្នាថា អំឡុងពេលរួមរស់ជាមួយគ្នាជាប្ដី-ប្រពន្ធ ពួកខ្លួនពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួមទេ គប្បីតុលាការមិនពិចារណា និងសម្រេចអំពីចំណុចបន្ទាប់បន្សំ ដូចមានបញ្ញត្តិក្នុងមាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនេះទេ។

៦.ភាគីដើមចោទឈ្មោះ [redacted] វិសាល បានអះអាងទទួលបង់ប្រាក់ប្រដាប់ក្ដី ហើយភាគីចុងចម្លើយទទួលស្គាល់នូវការអះអាងនេះ យោងតាមបញ្ញត្តិមាត្រា ៦៤ និងមាត្រា ៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមការព្រមព្រៀង។

**សេចក្ដីសម្រេចបញ្ចប់**

១. ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] វិសាល ក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ ដែលបានប្ដឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] គឹមអាត។

២.សម្រេចឲ្យភាគីដើមចោទឈ្មោះ [redacted]វិសាល លែងលះពីចុងចម្លើយឈ្មោះ [redacted] គឹមអាត។

៣.កំណត់យកម្ដាយឈ្មោះ [redacted] គឹមអាត ជាអ្នកមានអំណាចមេបាលើកូនទាំង ០២រូប កូនទី១ ឈ្មោះ [redacted] បញ្ញាពេជ្រ ភេទស្រី កើតថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៣ និងកូនទី២ ឈ្មោះ [redacted] បញ្ញាមរកត ភេទស្រី កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

៤.បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] វិសាល ផ្តល់ប្រាក់ជាសោហ៊ុយចាំបាច់សម្រាប់មើលថែរក្សាកូនទាំង ០២រូបខាងលើ ក្នុងមួយខែៗ ចំនួន ៤០០.០០០រ (សែសិបម៉ឺនរៀល) រហូតកូនពេញវ័យនីតិភាព ឲ្យទៅចុងចម្លើយឈ្មោះ [redacted] គឹមអាត។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ។

សាលក្រមនេះ ប្រកាសនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខដើមចោទឈ្មោះ [redacted] វិសាល និងចុងចម្លើយឈ្មោះ [redacted] គឹមអាត។

*ទុកសិទ្ធិឲ្យភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។*

ថ្ងៃច័ន្ទ ៤កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ព្រះវិហារ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃច័ន្ទ ៤កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ព្រះវិហារ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner